# 育成就労実施者の変更希望の申出書
# ពាក្យជូនដំណឹងអំពីបំណងផ្លាស់ប្តូរអ្នកអនុវត្តការបណ្តុះបណ្តាលនិងការងារ

下記のとおり、外国人の育成就労の適正な実施及び育成就労外国人の保護に関する法律第８条の２第１項に基づき、育成就労実施者の変更の希望を申し出ます。

ដោយផ្អែកតាមច្បាប់មាត្រា 8-2 កថាខណ្ឌទី 1 ដែលទាក់ទងនឹងការអនុវត្តត្រឹមត្រូវនូវការបណ្តុះបណ្តាលនិងការងារសម្រាប់ពលករបរទេសនិងការការពារពលករបរទេសនៃការបណ្តុះបណ្តាលនិងការងារ ខ្ញុំសូមជូនដំណឹងអំពីបំណងផ្លាស់ប្តូរអ្នកអនុវត្តការបណ្តុះបណ្តាលនិងការងារដូចដែលពិពណ៌នាខាងក្រោម ។

記
ពិពណ៌នា

| | |
|---|---|
| 合格している技能試験<br>ការប្រឡងជំនាញដែលប្រឡងជាប់ | |
| 合格している日本語能力の試験<br>ការប្រឡងសមត្ថភាពភាសាជប៉ុនដែលប្រឡងជាប់ | |
| 現在の育成就労実施者の下で育成就労の対象となっている期間（※）<br>រយៈពេលដែលចូលជាគោលដៅនៃការបណ្តុះបណ្តាលនិងការងារក្រោមអ្នកអនុវត្តការបណ្តុះបណ្តាលនិងការងារបច្ចុប្បន្ន (*) | |

※　申出をした時点での期間を記載してください。
សូមសរសេររយៈពេលគិតត្រឹមពេលដាក់ពាក្យស្នើជូនដំណឹង។

□　現在の育成就労実施者の下で育成就労を続けることができない事情がある。
ខ្ញុំមានហេតុផលដែលមិនអាចបន្តការបណ្តុះបណ្តាលនិងការងារក្រោមអ្នកអនុវត្តការបណ្តុះបណ្តាលនិងការងារបច្ចុប្បន្ន។

※　チェックした場合、以下を記載してください。
បើអ្នកបានគូសធីកប្រអប់នេះ សូមបំពេញព័ត៌មានខាងក្រោម។

<table>
<tr><td rowspan="3">育成就労実施者又は監理支援機関への相談状況<br>ស្ថានភាពពិគ្រោះយោបល់ជាមួយអ្នកអនុវត្តការបណ្តុះបណ្តាលនិងការងារ ឬស្ថាប័នមើលការខុសត្រូវនិងគាំទ្រ</td><td>相談時期（※１）<br>ពេលវេលាពិគ្រោះ (*1)</td><td colspan="2">相談した人（※２）<br>អ្នកពិគ្រោះជាមួយ (*2)</td><td>相談結果（※３）<br>លទ្ធផលពិគ្រោះ (*3)</td></tr>
<tr><td rowspan="2">______年___月___日<br>ឆ្នាំ ខែ ថ្ងៃទី</td><td colspan="2">監理支援機関／育成就労実施者<br>ស្ថាប័នមើលការខុសត្រូវនិងគាំទ្រ / អ្នកអនុវត្តការបណ្តុះបណ្តាលនិងការងារ</td><td rowspan="2">□　対応してくれない<br>មិនទទួលបានការឆ្លើយតប<br>□　対応が不十分<br>ឆ្លើយតបមិនបានគ្រប់គ្រាន់</td></tr>
<tr><td>氏　名<br>ឈ្មោះ</td><td></td></tr>
<tr><td>育成就労を続けることができない事情<br>ហេតុផលដែលមិនអាចបន្តការបណ្តុះបណ្តាលនិងការងារ</td><td colspan="4">別紙のとおり<br>ដូចមានក្នុងឧបសម្ព័ន្ធ</td></tr>
</table>

（※１）監理支援機関又は育成就労実施者に最初に相談した日を記載してください。相談を行っていない場合は記載不要です。
សូមសរសេរថ្ងៃដែលបានពិគ្រោះលើកដំបូងជាមួយស្ថាប័នមើលការខុសត្រូវនិងគាំទ្រឬអ្នកអនុវត្តការបណ្តុះបណ្តាលនិងការងារ។ មិនចាំបាច់បំពេញទេ បើមិនបានពិគ្រោះ។
（※２）監理支援機関又は育成就労実施者を○で囲み、相談した人の氏名を記載してください。
សូមគូសរង្វង់ជុំវិញស្ថាប័នមើលការខុសត្រូវនិងគាំទ្រ ឬអ្នកអនុវត្តការបណ្តុះបណ្តាលនិងការងារ ហើយសរសេរឈ្មោះអ្នកដែលបានពិគ្រោះជាមួយ។
（※３）該当欄に✓を付けてください。
សូមគូសសញ្ញា✓ ក្នុងកូឡោនដែលចូលលក្ខខណ្ឌ។

年　　月　　日
ឆ្នាំ　　ខែ　　ថ្ងៃទី

育成就労外国人（申出者）の署名
ហត្ថលេខារបស់ពលករបរទេសនៃការបណ្តុះបណ្តាលនិងការងារ(អ្នកជូនដំណឹង)

---

申出書を受領しました。
យើងបានទទួលពាក្យជូនដំណឹងហើយ។

年　　月　　日
ឆ្នាំ　　ខែ　　ថ្ងៃទី

受領者の署名 ＿＿＿＿＿＿＿＿
ហត្ថលេខាអ្នកទទួល ＿＿＿＿＿＿＿＿
受領者の所属機関 ＿＿＿＿＿＿＿＿
ស្ថាប័នរបស់អ្នកទទួល ＿＿＿＿＿＿＿＿
役職名 ＿＿＿＿＿＿＿＿
ឈ្មោះមុខតំណែង ＿＿＿＿＿＿＿＿

別　紙
ឧបសម្ព័ន្ធ

育成就労を続けることができない事情として、あなたに該当する事情を選んで該当欄に✓を付けた上で、その事情を次頁に具体的に記入してください（複数選択可）。

សូមជ្រើសរើសហេតុផលដែលមិនអាចបន្តការបណ្តុះបណ្តាលនិងការងារដែលត្រូវនឹងអ្នក ហើយគូសសញ្ញា✓ ក្នុងកូឡោនត្រូវនឹងអ្នកនៃជម្រើសនោះ រួចបំពេញឲ្យបានជាក់លាក់អំពីហេតុផលនោះនៅទំព័របន្ទាប់ (អាចជ្រើសរើសច្រើនជម្រើសបាន)។

| 番号<br>លេខរៀង | 現在の育成就労実施者での育成就労を続けることができない事情<br>ហេតុផលដែលមិនអាចបន្តការបណ្តុះបណ្តាលនិងការងារក្រោមអ្នកអនុវត្តការបណ្តុះបណ្តាលនិងការងារបច្ចុប្បន្ន | 該当<br>ត្រូវនឹងអ្នក |
|---|---|---|
| 1 | 私が暴行、暴言、嫌がらせをされた、私の同僚が人権侵害を受け、私も怖い思いをしたなど、人権を侵害された。<br>មានការបំពានសិទ្ធិមនុស្ស ដូចជា ខ្ញុំរងអំពើហិង្សា រងការប្រមាថ ឬទទួលការយាយី ឬអ្នករួមការងារខ្ញុំរងការបំពានសិទ្ធិមនុស្សហើយខ្ញុំក៏មានអារម្មណ៍ភ័យខ្លាចជាដើម។ | |
| 2 | 育成就労実施者から、クビだ、などと解雇する旨を告げられた。<br>អ្នកអនុវត្តការបណ្តុះបណ្តាលនិងការងារបានប្រាប់អំពីការបញ្ឈប់ការងារដូចជាថា ដេញអ្នកចោលហើយ ជាដើម។<br>（例）育成就労実施者の経営上の都合により育成就労外国人の雇用を継続できない場合<br>(ឧទាហរណ៍) ករណីមិនអាចបន្តជួលពលករបរទេសនៃការបណ្តុះបណ្តាលនិងការងារដោយហេតុផលផ្នែកការគ្រប់គ្រងអាជីវកម្មរបស់អ្នកអនុវត្តការបណ្តុះបណ្តាលនិងការងារ។ | |
| 3 | 退職合意書にサインするなど、育成就労実施者と雇用契約を解除する旨の合意をした。<br>បានយល់ព្រមបញ្ចប់កិច្ចសន្យាការងារជាមួយអ្នកអនុវត្តការបណ្តុះបណ្តាលនិងការងារ ដូចជាចុះហត្ថលេខាលើលិខិតយល់ព្រមឈប់ពីការងារជាដើម។ | |
| 4 | 育成就労実施者が重大悪質な法令違反行為を行った。<br>អ្នកអនុវត្តការបណ្តុះបណ្តាលនិងការងារ បានប្រព្រឹត្តល្មើសច្បាប់និងបទប្បញ្ញត្តិធ្ងន់ធ្ងរនិងទុច្ចរិត។<br>※　具体的に該当するものを 4-1～4-6 から全て選んでください。少しでも法令違反があれば必ず転籍できるというわけではなく、法令違反の態様が重大・悪質と認められる場合に転籍できることに注意してください。<br>សូមជ្រើសរើសជម្រើសដែលចូលលក្ខខណ្ឌជាក់លាក់ ទាំងអស់ ពី4-1 ដល់4-6។ សូមចំណាំថា មិនមែនឲ្យតែមានការល្មើសច្បាប់និងបទប្បញ្ញត្តិតែបន្តិចក៏អាចផ្លាស់ក្រុមហ៊ុនបាននោះទេ គឺអាចផ្លាស់ក្រុមហ៊ុនបានក្នុងករណីដែលការល្មើសច្បាប់និងបទប្បញ្ញត្តិនោះត្រូវបានរកឃើញថាមានសភាពធ្ងន់ធ្ងរនិងទុច្ចរិត។ | |
| 4-1 | 育成就労計画に記載された作業と異なる作業をした、育成就労計画に記載された作業時間と大きく異なる時間働いた、育成就労実施者とは異なる会社や人の指示の下で働いたなど、育成就労計画と大きく異なる育成就労をした。<br>បានធ្វើការបណ្តុះបណ្តាលនិងការងារដែលខុសគ្នាខ្លាំងពីផែនការការបណ្តុះបណ្តាលនិងការងារ ដូចជាបានធ្វើការងារដែលខុសពីការងារដែលមានសរសេរក្នុងផែនការការបណ្តុះបណ្តាលនិងការងារ ឬបានធ្វើការនៅពេលវេលាដែលខុសគ្នាខ្លាំងពីពេលវេលាធ្វើការងារដែលមានសរសេរក្នុងផែនការការបណ្តុះបណ្តាលនិងការងារ ឬបានធ្វើការក្រោមការបង្គាប់របស់ក្រុមហ៊ុនឬមនុស្សដែលខុសពីអ្នកអនុវត្តការបណ្តុះបណ្តាលនិងការងារជាដើម។ | |
| 4-2 | 多額の未払い賃金がある。<br>មានប្រាក់ឈ្នួលដែលមិនទាន់ត្រូវបានបង់ឲ្យ ក្នុងចំនួនច្រើន។ | |
| 4-3 | 時間外労働に対して安い賃金しか支払わない約束をした、製品を１個作るごとに賃金を支払う約束をしたなど、認定計画と異なる契約をした。<br>បានធ្វើកិច្ចសន្យាដែលខុសពីផែនការដែលត្រូវបានទទួលស្គាល់ ដូចជាបានសន្យាធ្វើការបន្ថែមម៉ោងដោយត្រូវបានបង់ប្រាក់ឈ្នួលទាប ឬបានសន្យាបង់ប្រាក់ឈ្នួលសម្រាប់រាល់ការផលិតផលិតផលមួយជាដើម។ | |
| 4-4 | 賃金から監理支援費を控除された、在留カードやパスポート、スマートフォンを取り上げられた、受入れ先からいなくなったら罰金を支払う約束をさせられたなど、育成就労法に違反する行為をされた。<br>បានរងសកម្មភាពដែលល្មើសច្បាប់ស្តីពីការបណ្តុះបណ្តាលនិងការងារ ដូចជាត្រូវបានកាត់ទុកថ្លៃមើលការខុសត្រូវនិងគាំទ្រពីក្នុងប្រាក់ឈ្នួល ឬត្រូវបានដកហូតប័ណ្ណស្នាក់នៅ លិខិតឆ្លងដែន ឬទូរសព្ទដៃ ឬត្រូវបានឲ្យសន្យាបង់ប្រាក់ពិន័យបើលែងនៅក្រុមហ៊ុនទទួលយក ជាដើម។ | |
| 4-5 | 長時間の時間外労働や休日労働をさせられた、危険な作業にもかかわらず危険を防止する措置がとられなかったなど、労働基準関係法令に違反する行為をされた。<br>បានរងសកម្មភាពដែលល្មើសច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងស្តង់ដាការងារ ដូចជាត្រូវបានឲ្យធ្វើការបន្ថែមម៉ោងឬធ្វើការនៅថ្ងៃឈប់សម្រាកច្រើនម៉ោង ឬមិនមានចាត់វិធានការការពារគ្រោះថ្នាក់ទាំងដែលការងារនោះជាការងារគ្រោះថ្នាក់ ជាដើម។ | |
| 4-6 | その他重大悪質な法令違反行為 | |

| | | | |
|---|---|---|---|
| | | សកម្មភាពផ្សេងទៀតដែលល្មើសច្បាប់និងបទប្បញ្ញត្តិធ្ងន់ធ្ងរ និងទុច្ចរិត | |
| 5 | | 育成就労実施者と交わした「雇用契約書及び雇用条件書」や「育成就労の期間中の待遇に関する重要事項説明書」で示されている労働条件や待遇と、実際の労働条件や待遇が違っている。<br>លក្ខខណ្ឌការងារនិងអត្ថប្រយោជន៍ជាដើមក្នុងភាពជាក់ស្តែង គឺខុសពី លក្ខខណ្ឌការងារឬអត្ថប្រយោជន៍ជាដើម ដែលមានបង្ហាញក្នុង"កិច្ចសន្យាការងារនិងឯកសារលក្ខខណ្ឌការងារ" ឬ "ឯកសារពន្យល់ពីចំណុចសំខាន់ទាក់ទងនឹងអត្ថប្រយោជន៍កំលុងពេលការបណ្តុះបណ្តាលនិងការងារ" ដែលបានចុះជាមួយអ្នកអនុវត្តការបណ្តុះបណ្តាលនិងការងារ។<br>※　具体的に違いが生じている労働条件や待遇を 5-1～5-7 から全て選んでください。労働条件や待遇が少しでも違っていれば必ず転籍できるわけではなく、育成就労実施者がその違いを是正しないなど、その違いが重大悪質と認められる場合に転籍できることに注意してください。<br>សូមជ្រើសរើសលក្ខខណ្ឌការងារនិងអត្ថប្រយោជន៍ដែលមានភាពខុសគ្នា ឲ្យជាក់លាក់ទាំងអស់ពី 5-1 ដល់ 5-7។ សូមចំណាំថា មិនមែនឲ្យតែមានភាពខុសគ្នាតែបន្តិចក្នុងលក្ខខណ្ឌការងារឬអត្ថប្រយោជន៍ក៏អាចផ្លាស់ក្រុមហ៊ុនបាននោះទេ គឺអាចផ្លាស់ក្រុមហ៊ុនបានក្នុងករណីដែលភាពខុសគ្នានោះត្រូវបានទទួលស្គាល់ថាធ្ងន់ធ្ងរនិងទុច្ចរិត ដូចជាអ្នកអនុវត្តការបណ្តុះបណ្តាលនិងការងារ មិនកែតម្រូវភាពខុសគ្នានោះជាដើម។ | |
| | 5-1 | 就業（育成就労）の場所、従事する業務の内容に関すること<br>បញ្ហាទាក់ទងនឹង ទីតាំងបំពេញការងារ (ការបណ្តុះបណ្តាលនិងការងារ) ខ្លឹមសារនៃការងារដែលត្រូវបំពេញ | |
| | 5-2 | 休憩時間や所定労働時間、時間外労働の有無など、労働時間に関すること<br>បញ្ហាទាក់ទងនឹងម៉ោងការងារដូចជា ម៉ោងសម្រាក ម៉ោងធ្វើការកំណត់ ការមានឬគ្មានការងារបន្ថែមម៉ោងជាដើម | |
| | 5-3 | 休日となる日や、有給休暇の日数など、休日・休暇に関すること<br>បញ្ហាទាក់ទងនឹងថ្ងៃឈប់សម្រាក/ការឈប់សម្រាកដូចជា ថ្ងៃដែលត្រូវជាថ្ងៃឈប់សម្រាក ចំនួនថ្ងៃនៃការឈប់សម្រាកមានប្រាក់ឈ្នួលជាដើម | |
| | 5-4 | 基本賃金や諸手当、時間外労働の割増賃金率、賃金支払日、昇給、賞与、休業手当、賃金からの控除項目、１か月あたりの支払い概算額など、賃金に関すること<br>បញ្ហាទាក់ទងនឹងប្រាក់ឈ្នួល ដូចជាប្រាក់ឈ្នួលគោល ឬប្រាក់ឧបត្ថម្ភផ្សេងៗ អត្រាប្រាក់ឈ្នួលដំឡើងសម្រាប់ការងារបន្ថែមម៉ោង ថ្ងៃបង់ប្រាក់ឈ្នួល ការដំឡើងប្រាក់ឈ្នួល ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភពេលសម្រាកការងារ ចំណុចត្រូវកាត់ទុកពីប្រាក់ឈ្នួល ឬចំនួនទឹកប្រាក់ប៉ាន់ស្មាននៃការបង់ប្រចាំខែជាដើម | |
| | 5-5 | 宿泊施設の広さ、場所、負担額など、宿泊施設に関すること<br>បញ្ហាទាក់ទងនឹងកន្លែងស្នាក់នៅ ដូចជាទំហំកន្លែងស្នាក់នៅ ទីតាំង ឬទឹកប្រាក់បន្ទុកជាដើម | |
| | 5-6 | 入国後講習中の手当、食費、居住費など、入国後講習中の待遇に関すること<br>បញ្ហាទាក់ទងនឹងអត្ថប្រយោជន៍ក្នុងកំលុងវគ្គសិក្សាក្រោយចូលប្រទេសជប៉ុន ដូចជាប្រាក់ឧបត្ថម្ភ ថ្លៃម្ហូបអាហារ និងថ្លៃស្នាក់នៅជាដើម ក្នុងកំលុងវគ្គសិក្សាក្រោយចូលប្រទេសជប៉ុន | |
| | 5-7 | その他の労働条件や待遇に関すること<br>លក្ខខណ្ឌការងារនិងអត្ថប្រយោជន៍ផ្សេងទៀត | |
| 6 | | 雇用契約締結時に雇用契約書や雇用条件書が交付されていない、又は雇用条件や待遇について母国語で説明を受けていない。<br>មិនបានទទួលការចេញឲ្យនូវកិច្ចសន្យាការងារ ឬឯកសារលក្ខខណ្ឌការងារជាដើម នៅពេលចុះកិច្ចសន្យាការងារ ឬមិនបានទទួលការពន្យល់ជាភាសាកំណើត ទាក់ទងនឹងលក្ខខណ្ឌការងារ ឬអត្ថប្រយោជន៍ជាដើម។ | |
| 7 | | 現在の育成就労実施者で育成就労を続けることができないその他の事情がある。<br>（例）育成就労実施者で取り扱う食品等に対するアレルギーや疾病を発症し、育成就労継続が困難になった場合や日常生活に支障をきたすようになった場合等<br>មានហេតុផលផ្សេងទៀតដែលមិនអាចបន្តការបណ្តុះបណ្តាលនិងការងារក្រោមអ្នកអនុវត្តការបណ្តុះបណ្តាលនិងការងារបច្ចុប្បន្ន។<br>(ឧទាហរណ៍)<br>ករណីពិបាកបន្តការបណ្តុះបណ្តាលនិងការងារឬករណីជួបឧបសគ្គក្នុងការរស់នៅប្រចាំថ្ងៃ ដោយសារកើតអាលែកហ្ស៊ីឬជំងឺដោយសារផលិតផលជាដើមដែលធ្វើការជាមួយនៅអ្នកអនុវត្តការបណ្តុះបណ្តាលនិងការងារ | |

選んだ番号の事情を、できるだけ具体的に記載してください。
សូមសរសេរឲ្យបានជាក់លាក់តាមដែលអាច អំពីហេតុផលក្នុងលេខដែលបានជ្រើសរើស។

（例）

(ឧទាហរណ៍)

1 : ○月○日頃、○○をした際、○○から頭を叩かれた。
នៅអំឡុងខែ ○ ថ្ងៃទី ○ ពេលខ្ញុំធ្វើ○○ ស្រាប់តែ○○វាយក្បាលខ្ញុំ។

4-2・5-4 : ○月頃から賃金が支払われなくなり、現在○円くらいの賃金が支払われていない。
មិនត្រូវបានបង់ប្រាក់ឈ្នួលតាំងពីអំឡុងខែ○ ហើយបច្ចុប្បន្ន ប្រាក់ឈ្នួលប្រហែល○យ៉េនមិនទាន់បានបង់មកនៅឡើយទេ។

5-3 : ○月○日頃、有給休暇を申請したのに、取得させてくれない。
នៅអំឡុងខែ○ថ្ងៃទី○ ខ្ញុំបានស្នើសុំប្រើការឈប់សម្រាកដោយមានប្រាក់ឈ្នួល ប៉ុន្តែមិនត្រូវបានផ្តល់ទេ។